# អំពី « ស្ត្រីភាព »

**សិក្សាដោយ ឱម ខែម**

ពាក្យ « ស្រី » មួយម៉ាត់ ដែលខ្មែរយើងប្រើជាឈ្មោះមនុស្សស្រីនោះ ឃ្លាតមកពីពាក្យសំស្រ្កឹត ថា « ស្ត្រី » គឺមនុស្សជាតិដែលមានភេទទីទៃពីបុរស, ទីទៃពីខ្ទើយ ។ ភាសាបាលីថា «ឥត្ថី » ប្រែតាម ន័យវចនានុក្រមខ្មែរថា « **មនុស្សដែលបុរសគួរចង់បាន, ដែលជាគូរនឹងបុរស** » ។

ពាក្យ « ស្រី » មួយម៉ាត់ទៀត (សំ.) ដែលខ្មែរយើងច្រើនប្រើជាពាក្យរួមពីខាងដើមស័ព្ទដទៃ, ដូចជា *ព្រះស្រីសព្វជ្ញ* (ព្រះសម្ពុទ្ធ), *ស្រីសួស្តី, ស្រីស្រីង្គារ* ស្រីដែលមានលំអគួរឲ្យកើតសេចក្តីស្រលាញ់,....។ ភាសាបាលីថា « សិរី » ប្រែថា លំអដែលគួរឲ្យកើតសេចក្តីស្រលាញ់, សួស្តី, មង្គល, ជោគ, សេចក្តីសុខ, សេចក្តីចំរើន, បុណ្យ, ភ័ព្វ, ព្រេងសំណាង, អំណាច, តេជះ ។

តទៅនេះ យើងនឹងលើកយក *ភេទ លំអ* និងករណីយកិច្ចរបស់ « **ស្ត្រីភាព** » មកពិចារណាដូចតទៅ:

ក) **ភេទរបស់ស្ត្រី:** តាមធម្មជាតិ ជាភេទខ្សោយ សាច់ទន់ជ្រាយ កាយទន់ភ្លន់ ចិត្តទន់ ឆាប់ខឹង ឆាប់ជា, ផ្ទុយពីភេទបុរសដែលជាខ្លាំង សាច់រឹង កាយរឹងប៉ឹង ចិត្តរឹង ក្រខឹង ក្រជា ។

រឿងខ្សោយ រឿងខ្សោយនេះ មិនថាតែភេទមនុស្សជាស្រីជាប្រុសនោះទេ សូម្បីតែភេទសត្វជាញីជាឈ្មោល ក៏ដូចគ្នា ។

ខ) **លំអរបស់ស្ត្រី:** ក្នុងគម្ពីរធម្មបទខុទ្ទកនិកាយ មាននិយាយពីលំអប្រាំប្រការរបស់ស្ត្រី (បញ្ចពិធកល្យាណី) ពោលគឺ លំអរបស់នាងវិសាខា ។ លំអទាំង ៥ នោះគឺ:

| | |
|---|---|
| *១. កេសកល្យាណ* | លំអសក់ |
| *២. មំសកល្យាណ* | លំអសាច់ |
| *៣. អដ្ឋិកល្យាណ* | លំអឆ្អឹង លំអធ្មេញ |
| *៤. ឆវិកល្យាណ* | លំអសម្បុរស្បែក |
| *៥. វយកល្យាណ* | លំអវ័យ (ចាំសាច់) ។ |

លំអទាំង ៥ នេះ នាងវិសាខាមានគ្រប់ តាំងពីបឋមវ័យ រហូតដល់បច្ឆិមវ័យ។ ឯស្ត្រីដទៃទៀត មិនអាចរក្សាលំអទាំង ៥ បានគ្រប់វ័យទេ ។

មានលំអ ៣ ប្រការដោយឡែក ដែលគេឲ្យតម្លៃលើលំអស្ត្រីខ្មែរគឺ ល្អរូប ល្អរាង និងល្អពៅ ។

ព្រះភិក្ខុ ញ៉ែម គឹមតេង ប្រធានអង្គការសន្តិសេនា នៅខេត្តស្វាយរៀង បានមានពុទ្ធដីកាបំភ្លឺអំពីន័យនៃលំអទាំង ៣ ប្រការនេះថា:

**ល្អរូប** គឺមានរូបសម្បត្តិល្អណាស់ ទាំងញញឹមក៏ស្រស់ទៀត,

**ល្អរាង** គឺរូបភាព ហៅថាសណ្ឋានរាងល្អ

**ល្អវៅ** គឺសំដៅយកអាកប្បកិរិយាល្អ,មារយាទថ្លៃថ្នូរ, ចិត្តគំនិងស្លូតបូត សុភាពរាបសារ ។

គ) **ករណីយកិច្ចរបស់ស្ត្រី:** ធម្មជាតិគាត់តែងស្ត្រីមក សម្រាប់ធ្វើជាមាតារបស់លោក សំរាប់ចិញ្ចឹមបុត្រធីតា ថែរក្សាគ្រឹះស្ថាន និងទ្រព្យសម្បត្តិ ។

តាំងពីដើមបឋមភទ្ទកប្បមក មនុស្សក្នុងលោកគ្រប់ប្រទេស គេនិយមទុកស្ត្រីឲ្យនៅតាមធម្មជាតិ គឺគេមិនឲ្យពួកស្ត្រីធ្វើការធ្ងន់, ប្រើកំលាំងខ្លាំង ដូចជាលើកដាក់ លីសែង កាប់គាស់ វាយដំធ្វើចម្បាំងជាដើមនោះទេ, ភារៈទាំងនេះ គេទុកជាភារៈខាងពួកបុរស, ឯពួកខាងស្ត្រី គេប្រើតែខាងការងារស្រាលៗ ដូចជា ស្លដាំ ដេរប៉ាក់ ថែទាំកូនចៅ ជាដើម ។ និយាយដោយខ្លីគឺ ប្រុសៗជាអ្នកធ្វើការនៅព្រៃ ស្រីៗជាអ្នកធ្វើការនៅផ្ទះ ។

សម័យបុរាណ, ប្រទេសខ្លះ គេថ្នមពួកស្ត្រីដល់ទៅយកសំពត់រុំជើងតាំងពីតូចៗ ដើម្បីកុំឲ្យដើរឆ្ងាយពីផ្ទះ ជាការទប់ភេទស្ត្រីឲ្យនៅតាមធម្មជាតិ, ប៉ុន្តែឥឡូវនេះប្រពៃណីនេះរលុបបាត់អស់ទៅហើយ ។

ប្រទេសខ្មែរយើង ក៏និយមទុកពួកស្ត្រីឲ្យប្រព្រឹត្តទៅតាមធម្មជាតិដើមដែរ ។ សម័យបុរាណ, អ្នកស្រុកមិនឲ្យស្ត្រីរៀនអក្សរ, គេនិយាយបន្លាចគ្នាថា « ***មិនត្រូវឲ្យរៀនអក្សរ ព្រោះតែរៀនចេះទៅនឹងសរសេរសំបុត្រទៅរកប្រុសឈ្មោលតាមអំពើចិត្ត*** » ។ ពាក្យបន្លាចនេះ បានធ្វើឲ្យស្ត្រីខ្មែរច្រើនភាគរយមិនចេះអក្សរ, ប៉ុន្តែ សម័យបច្ចុប្បន្ន គេលែងឮពាក្យបន្លាចនេះទៀតហើយ, គេត្រឡប់ជាឮនិយាយប្រាប់គ្នាថា ត្រូវតែឲ្យស្ត្រីរៀនសូត្រគ្រប់មុខវិជ្ជា ដើម្បីសេចក្តីរីកចំរើននៃប្រទេសជាតិ ។

ក្រោយពេលប្រទេសជាតិបានរំដោះរួចពីរបបប្រល័យពូជសាសន៍នាឆ្នាំ១៩៧៩ ជាពេលដែលចាប់ផ្តើមកសាងមាតុប្រទេសពីកំរិតទាបគេឃើញពាក្យស្លោកថា «**នារីជាមាតានៃពិភពលោក**», «**គ្មាននារីចូលរួមមិនអាចកសាងសង្គមបានឡើយ** » ។ នេះជាពាក្យស្លោកមានតម្លៃអប់រំ តម្លៃវប្បធម៌ និងតម្លៃ នយោបាយ ។ ដោយសារការអនុវត្តពាក្យស្លោកនេះ ទើបមានកំលាំងនារីចូល រួមការងារសង្គមយ៉ាងផុលផុស ។ នៅក្នុងករណីយកិច្ចនិងកាតព្វកិច្ចរបស់ខ្លួន នារីកម្ពុជាមានគុណសម្បត្តិច្រើនក្នុងការចូលរួមចំណែកស្តារ កសាង និងការពារមាតុភូមិ ។

ពិតមែនតែធម្មជាតិតាក់តែងឲ្យស្ត្រីមានភេទខ្សោយ សាច់ទន់ជ្រាយ កាយមិនរឹងប៉ឹង ចិត្តទន់ ប៉ុន្តែ ស្ត្រីអាចបង្ហាត់កាយរបស់ខ្លួនតាមក្បួនអនាម័យ និងអត្តពលកម្មឲ្យរឹងប៉ឹង ឲ្យរហ័សរហួន, អប់រំចិត្តតាមក្បួនសិក្សាឲ្យមានប្រាជ្ញាវាងវៃប៉ិនប្រសប់លើសធម្មតាបាន មិនអន់ជាងបុរសប៉ុន្មានទេ ជួនកាលមានគ្រាន់បើជាងបុរសខ្លះដោយអន្លើៗផង ប្រសិនជាគេព្យាយាមហ្វឹកហាត់ និងអប់រំម៉ឺងម៉ាត់ម៉ត់ចត់ មែនទែន ។ យ៉ាងណាមិញ:

- *សម័យមុនពុទ្ធកាល:* មានស្ត្រីម្នាក់ឈ្មោះនាង «អមរា» ជាមហេសីនៃព្រះមហោសថ ពោធិសត្វ ជារាជបណ្ឌិតនៃព្រះបាទវិទេហរាជ ។ ថ្ងៃមួយ អាចារ្យទាំង ៤ នាក់ ដែលជាគូសត្រូវនឹងព្រះមហោសថ បានលួចកែវមណីព្រះរាជទ្រព្យទៅលក់អោយនាងអមរា, នាងបានទទួលទិញដោយកត់ឈ្មោះអ្នកលក់ ទាំងពេលទិញ, ហើយពួកអាចារ្យទូលព្រះមហាក្សត្រ មួលបង្កាច់ថាព្រះមហោសថលួច ។ ព្រះរាជាទ្រង់ព្រះបញ្ជាឲ្យហៅព្រះមហោសថ ។ ព្រះមហោសថឃើញថាកែខ្លួនពុំបាន ក៏ប្រាប់នាងអមរាថា គួរគៀសខ្លួនសិន ។ ពេលនោះ ពួកអាចារ្យចង់បាននាងអមរាជាភរិយា ក៏ឲ្យដំណឹងថា នឹងទៅជួបនាងក្នុងវេលាយប់នៅផ្ទះនាង ។ ឯនាងអមរា ឲ្យកម្មករជីករណ្តៅក្រោមផ្ទះដាក់លាមកក្នុងរណ្តៅនោះក្រាលក្តារពីលើ ធ្វើគន្លឹះឲ្យជាន់របូត ហើយក្រាលកម្រាលដូចអាសនៈធម្មតា ។ វេលាពួកអាចារ្យមកដល់ ដើរជាន់កម្រាល ក៏ធ្លាក់ទៅក្នុងរណ្តៅនោះរណ្តំក្បាលគ្នា។ នាងអមរា ក៏ឲ្យចាប់អាចារ្យទាំង ៤ នាក់ចងភ្ជាប់គ្នានាំទៅថ្វាយព្រះរាជា។ ព្រះអង្គទ្រង់ព្រះវិនិច្ឆ័យថា កំហុសនេះធ្លាក់ទៅលើអាចារ្យទាំង ៤ ។ ព្រះមហោសថរួចខ្លួនដោយសារនាងអមរាជាមហេសី ដែលជាស្ត្រីបានសិក្សា មានប្រាជ្ញាច្រើនជួយដោះកុន។
- *សម័យពុទ្ធកាល:* មានស្ត្រីម្នាក់ឈ្មោះនាង ខុជ្ជុត្តរា ជាស្ត្រីបំរើពួកព្រះស្នំរបស់ព្រះឧទេន ព្រះចៅក្រុងកោសម្ពីមានព្រះនាងសម្មាវតីជាដើមដែលព្រះរាជាទ្រង់ហាមពួកព្រះស្នំមិនឲ្យទៅស្តាប់ព្រះធម៌ទេសនារបស់ព្រះសម្មាសម្ពុទ្ធនៅក្រៅវាំង ។ ព្រះស្នំទាំងនោះបានចាត់ឲ្យនាងខុជ្ជុត្តរាទៅស្តាប់ធម៌ ហើយឲ្យនាំយកព្រះធម៌នោះមកសំដែងប្រាប់ព្រះស្នំ ។ នាងខុជ្ជុត្តរាបានទៅស្តាប់ និងបានសំដែងធម៌ឲ្យព្រះស្នំស្តាប់រាល់ថ្ងៃ ក៏បានទៅជាអ្នកប្រាជ្ញមួយរូប ពូកែខាងសំដែងធម៌ បានលាភសក្ការៈច្រើន ។

មានរឿងនិទានមួយទៀត ក្នុងសម័យពុទ្ធកាលដែរថា: មានស្ត្រីម្នាក់ឈ្មោះនាងកុណ្ឌលកេសី ជាកូននៃរាជគ្គហសេដ្ឋី នាងបានសុំឲ្យបិតាលោះចោរម្នាក់ដែលពេជ្ឈឃាតបណ្តើរយកទៅសំលាប់យកមកធ្វើប្តី ។ ចោរមកនៅផ្ទះសេដ្ឋី តែចង់ទៅនៅព្រៃវិញ, វាល្បួងនាងឲ្យជូនវាទៅព្រៃ ដើម្បីលាបំណន់ក្បែរមាត់ជ្រោះនៅជើងភ្នំមួយ វាឲ្យនាងស្លៀកពាក់ល្អ មានគ្រឿងមាសពេជ្រជាច្រើន ដើម្បីសំលាប់យកគ្រឿងប្រដាប់ស៊ីចាយ ។ លុះទៅដល់មាត់ជ្រោះ ចោរប្រុងសំលាប់នាង ។ នាងកុណ្ឌល

កេសីគិតថា *«ធម្មតាប្រាជ្ញដែលគេខំរៀនសូត្រមក គេមិនដែលយកវាទៅស្ងោរស៊ីជាអាហារទេ គេត្រូវប្រើវាដោះខ្លួនឲ្យផុតពីភ័យអាសន្ន »*។ លុះគិតហើយ នាងលួងចោរថា *«អ្នកបង! ខ្ញុំដឹងគុណណាស់ដែលអ្នកបានមកធ្វើជាប្តីខ្ញុំនេះ តែមុននឹងព្រាត់ចាកអ្នក ខ្ញុំសូមបូជាគុណអ្នកសិន សឹមស្លាប់»* ។ ថាហើយក៏សំពះទៅទិសទាំង ៤ ដើរប្រទក្សិណចោរ ៣ ជុំ ហើយច្រានចោរទម្លាក់ ជ្រោះស្លាប់ទៅ ។

កាលដែលចោរធ្លាក់ជ្រោះ ពួករុក្ខទេវតាដែលអាស្រ័យនៅព្រៃនោះក៏ស្រែកបន្លឺឲ្យសព្ទសាធុការថា:

*ន សោ សព្វេសុ ឋានេសុ បុរិសោ ហោតិ បណ្ឌិតោ*

*ឥត្ថីបិ បណ្ឌិតោ ហោតិ តត្ថ តត្ថ វិចក្ខណា ។*

**ប្រែថា: បុរសមិនមែនជាបណ្ឌិតគ្រប់ហេតុទាំងពួងទេ, ស្ត្រីក៏ជាបណ្ឌិតអាចពិចារណាក្នុង ហេតុនោះៗដែរ ។**

គឺថា: អ្នកប្រាជ្ញមិនមែនមានតែបុរសទេ, ស្ត្រីបើខំរៀនសូត្រចំណេះវិជ្ជាខាងផ្លូវលោកក្តី ខាងផ្លូវធម៌ក្តី ក៏បានជាអ្នកប្រាជ្ញដូចគ្នា ។

- ***នៅសម័យនគរភ្នំ*** (ហ្វូណន់) គ្រឹស្តសតវត្សទី១៖

យើងមានមេនាយកជាតិខេមរៈ ហើយជាស្ត្រីភាព បានតាំងខ្លួនជាស្តេច មានព្រះនាមជាក្សត្រិយ លីវយី ឬ សោម៉ា (កូនព្រះចន្ទ) ដែលខ្មែរហៅថា «នាងសក់ក្រអូប» ទ្រង់សោយរាជ្យលើកោះគោកធ្លក ឬ ប្រទេសខ្មែរ ។ មានព្រះរាជាមួយព្រះអង្គ ទ្រង់ចាកចេញពីប្រទេសឥណ្ឌាភាគខាងត្បូង ចូលមកកាន់ប្រទេសខ្មែរដំបូងបំផុត ព្រះនាម «ព្រះបាទកុមេរុ» ។ ព្រះរាជាអង្គនេះបានធ្វើសង្គ្រាមនឹងព្រះរាជិនីព្រះនាមលីវយី ។

កាលព្រះរាជិនីលីវយីចាញ់សង្គ្រាមហើយ ព្រះនាងក៏សព្វព្រះទ័យទទួលយកព្រះបាទកុមេរុជាព្រះស្វាមី អភិសេកសោយរាជ្យសម្បត្តិនៅនគរវ្នំ (ភ្នំ) ។ ព្រះមហាក្សត្រអង្គនេះហើយជាដើមព្រះរាជវង្ស គឺសន្តតិវង្សទី ១ នៃប្រទេសកម្ពុជា ។ រឿងនេះសរឲ្យឃើញថា ប្រទេសខ្មែរដំបូងបំផុត មានស្ត្រីខ្មែរជាស្តេចគ្រប់គ្រង ។

- ***សម័យអង្គរ*** (គ្រឹស្តសតវត្សទី ១៣) :

សិលាចារឹកនៅប្រាសាទអង្គរប្រាប់ថា *«ព្រះនាងអគ្គមហេសី នៃព្រះបាទជ័យវរ្ម័នទី៧ ពូកែលើសលប់ឥតនរណាស្មើខាងវិទ្យាសាស្ត្រ និង បរមត្ថសាស្ត្រ ព្រះរាជាទ្រង់តាំងជាបរិនាយិកាក្នុងព្រះអារាមព្រះពុទ្ធសាសនាដ៏ល្បីល្បាញមួយ ព្រះនាងបានបង្រៀនពួកស្ត្រី»* គឺព្រះនាងនេះហើយ ដែលធ្វើឲ្យយើងដឹងដោយសិលាចារឹកយ៉ាងធំមួយនៅប្រាសាទភិមានអាកាស ដែលព្រះនាងតែងដោយព្រះអង្គឯងថា៖ « *ព្រះនាងគង់នៅក្នុងទីកន្លែងមួយឈ្មោះនមន្ត្រាស្រមជាទីសិក្សា ដែលពួកស្ត្រីរាជបរិពារមករៀនសូត្រ ព្រះនាងមាននាមល្បីល្បាញក្នុងទីនោះ ដោយការគោរព*

*របស់សិស្សទាំងឡាយ ព្រះនាងក៏ធ្វើឲ្យពួកស្ត្រីទាំងនោះបានសេចក្ដីសុខ ឧបមាដូចជាទេវធីតាឈ្មោះសរស្វតីបែងនាំមក...ព្រះនាងបានផ្សាយសេចក្ដីមេត្តាព្រះមហាក្សត្រ ចំពោះស្ត្រីណាដែលចូលចិត្តសិក្សាវិទ្យាសាស្ត្រ ឧបមាដូចជាទឹកទិព្វយ៉ាងប្រសើរដែលហូរចេញមកជាសេចក្ដីចេះដឹង* » ។

- ***សម័យព្រះរាជវាំងកោះស្លាកែត*** (គ.ស. ១៨៣៤ ដល់ ១៨៤១) :

ប្រទេសកម្ពុជាមានស្ត្រីភាពជាព្រះរាជិនី គឺព្រះអង្គម៉ី ក្សត្រីព្រះរាជបុត្រីព្រះបាទឧទ័យរាជា (ព្រះអង្គចន្ទ) ស្ដេចឡើងសោយរាជ្យតំណពីព្រះវររាជបិតា គង់នៅក្នុងព្រះបរមរាជវាំងកោះស្លាកែត (ត្រើយពោធិ៍ព្រះបាទ) ក្នុងខេត្តកណ្ដាល ។ រជ្ជកាលនេះ ជារជ្ជកាលទី ៧៨ នៃសន្តតិវង្សប្រទេសកម្ពុជា, មុនរជ្ជកាលព្រះករុណាបរមកោដ្ឋ (អង្គដួង) ដែលគង់នៅព្រះបរមរាជវាំងឧត្តុង្គមានជ័យ ។

- ***សម័យភ្នំពេញ*** (គ.ស. ១៩៥៥) :

ប្រទេសកម្ពុជា មានព្រះមហាក្សត្រ ២ ព្រះអង្គ គឺព្រះករុណាជាអម្ចាស់ជីវិតតំកល់លើត្បូង ព្រះបាទសម្ដេចព្រះនរោត្តម សុរាម្រឹត ជាព្រះរាជស្វាមី និងសម្ដេចព្រះមហាក្សត្រិយានី ស៊ីសុវត្ថិ មុនីវង្ស កុសុមៈនារីរ័ត្ន សិរីវឌ្ឍនា ជាព្រះអគ្គមហេសី ទ្រង់ឡើងសោយរាជសម្បត្តិ ពីថ្ងៃទី ៣ ខែមីនា ឆ្នាំ ១៩៥៥ ជារជ្ជកាលទី ៨៤ នៃព្រះសន្តតិវង្សប្រទេសកម្ពុជា តំណពីរជ្ជកាលទី ៨៣ នៃព្រះករុណាព្រះបាទសម្ដេចព្រះនរោត្តម សីហនុ ព្រះរាជបុត្រដ៏ឆ្នើមរបស់ព្រះអង្គ ។

ការសិក្សារបស់យើងដោយសង្ខេបមកប៉ុណ្ណេះ បញ្ជាក់ឲ្យឃើញថាៈ ស្ត្រីភាពដែលធម្មជាតិតាក់មកជាភេទខ្សោយ សាច់ជ្រាយ កាយទន់ភ្លន់ ចិត្តមិនសូវរឹងប៉ឹងនោះ បើបណ្ដោយទុកតាមធម្មជាតិក៏ខ្សោយតាមដើម ប៉ុន្តែបើគេបានអប់រំបន្ទំនិស្ស័យដោយក្បួនអនាម័យ ក្បួនវិទ្យាសាស្ត្រ និងក្បួនសិក្សាយ៉ាងម៉ឺងម៉ាត់ ក៏ទៅជាមនុស្សខ្លាំង សាច់រឹង កាយរឹងប៉ឹង ចិត្តពូកែក្លាហាន មានប្រាជ្ញប៉ាធី ស្មើនឹងបុរសដែរ ឬពូកែជាងបុរសខ្លះដោយអន្លើក៏សឹងមាន ។
ព្រោះហេតុនោះបានជា មនុស្សលោកសម័យបច្ចុប្បន្ន គេនិយមឲ្យស្ត្រីធ្វើវិធីហាត់ប្រាណ ដើម្បីឲ្យស្ត្រីមានសុខភាព ឲ្យមានកំលាំងពលំរឹងប៉ឹង រហូតដល់អាចធ្វើជាទាហាន ឬជាពេទ្យទាហានទៅប្រតិបត្តិការងារក្នុងកងទ័ពបាន, ឲ្យស្ត្រីរៀនអក្សរដើម្បីឲ្យមានប្រាជ្ញាជ្រៅជ្រះ រហូតដល់ធ្វើជាសាស្ត្រាចារ្យ ជាអ្នករាជការកាន់មុខតំណែងធំៗបាន, ឲ្យរៀនសិល្បៈវិជ្ជាគ្រប់បែប ដើម្បីឲ្យបានជាសិល្បករ ជាហត្ថករ ឧស្សាហករ ពាណិជ្ជករ កសិករ និងកម្មករជំនាញៗសំរាប់ជំរុញសេដ្ឋកិច្ចរបស់ប្រទេសឲ្យមានវឌ្ឍនភាព -ល- ។

ប្រទេសកម្ពុជាយើង ចាប់តាំងពីសម័យរាជរដ្ឋាភិបាលសង្គមរាស្ត្រនិយម រហូតដល់សម័យរាជរដ្ឋាភិបាលបច្ចុប្បន្ន គឺឲ្យស្ត្រីមានសិទ្ធិស្មើនឹងបុរស, អាចបោះឆ្នោតជ្រើសតាំងតំណាងរបស់ខ្លួន, អាចឈរឈ្មោះជាបេក្ខជនឲ្យគេបោះឆ្នោតជ្រើសតាំងខ្លួនជាតំណាងរាស្ត្រ, ឲ្យស្ត្រីហាត់ប្រាណតាម

អត្តពលកម្មវិធី ឲ្យមានរាងកាយរឹងមាំ មានសុខភាព, ឲ្យហាត់កាន់កាំភ្លើង, ដូចក្នុងផែនការព្រះសីហនុ ដែលតាំងស្ត្រីខ្មែរឲ្យជានារីក្លាហាន ដំណាលគ្នានឹងបុរសដែលតាំងជាកងជីវពលកាន់កាំភ្លើងប្រតិបត្តិការសាមគ្គីមានជោគជ័យ ដរាបដល់ដណ្តើមយកឯករាជ្យពេញទីជូនមាតុប្រទេសបាន ពីថ្ងៃទី ៩ ខែវិច្ឆិកា ឆ្នាំ ១៩៥៣ ។

ឈានចូលដល់សតវត្សទី ២១, សតវត្សនៃអរិយធម៌ខាងស្មារតី, អនាគតនៃប្រទេសកម្ពុជាយើង នឹងមានវឌ្ឍនភាពដោយសារកំលាំងស្ត្រីខ្មែរ ដែលមានចំណេះដឹង ចំណេះធ្វើ ហើយរួបរួមគ្នាការពារនិងអភិវឌ្ឍប្រទេសជាតិ ឲ្យបានរីកចំរើនជាភិយ្យោភាព ក្រោមបាវចនា ជាតិ សាសនា ព្រះមហាក្សត្រ ស្របតាមន័យនៃគតិបណ្ឌិតថា ៖ *ស្ត្រីជាពលភាពប្រទេសជាតិ អាចជួយប្រុសរាំគសកម្មភាព ជួយជាតិសាសនាប្រាជ្ញត្រូវជ្រាប យោងដីសំណាបស្រីយោងប្រុស* ៕

ដកស្រង់ចេញពី **កម្ពុជសុរិយា**

ទស្សនាវដ្តី ផ្សាយអក្សរសាស្ត្រសាសនា និង អក្សរសាស្ត្រទូទៅ

ពីពុទ្ធសាសនបណ្ឌិត្យ

*ឆ្នាំទី ៥៥ លេខ ៣ ព.ស. ២៥៤៤, ខែកក្កដា - សីហា - កញ្ញា គ.ស. ២០០០*

....

***ភិក្ខុវណ្ណគុត្តោ ស្វាត សាលឿម***

www.bodhikaram.com

.............................................................................

# គតិបណ្ឌិត: *សំណាបយោងដី...*

**«សំណាបយោងដី ស្រីយោងប្រុស ពូថៅយោងខ្លស ច្រមុះយោងថ្ពាល់»**

..........

*សិល្បៈសំដី*

*បុរាណកវី ប្រៀបធៀបឧបមា*
*កំប៉ុកកំប៉្លែង ថ្លែងរាយរ៉ោហា*
*បង្កប់ខ្លឹមសារ មានជ្រៅមានរាក់ ។*

**សំណាបយោងដី**

*គតិប្រពៃ ក្នុងន័យបញ្ជាក់*
*សំណាបណាល្អ បវរពេញលក្ខណ៍*
*ទោះអស់លោកអ្នក យកស្ទូងស្រែណា ។*

*ស្រែត្រោកស្រែត្រាច*

*ស្រែវាលប៉ាចហាច គង់បានផលា*
*ស្ទូងហើយលូតលាស់ បង្ហាញកាយា*
*គេតែងពោលថា ស្រែនោះដីល្អ ។*

**ឯស្រីយោងប្រុស**

*លោកថាមិនខុស មានក្លាយជាក្រ*
*ដូចនាយសំពៅ យកពេជ្រដូរថ្ម*
*ក្បត់ចិត្តស្មោះសរ ពីស្នួនភរិយា ។*

*ឃើញនាងនារី*

*ស្រីអលង្គី មានរូបសោភា*
*ប្រពន្ធមាណព តាមដងជលធា*
*កំពុងនាំគ្នា ជញ្ជាត់ចាប់ត្រី ។*

*រឿងតូចតាចសោះ*

បង្កើតជម្មោះ ដូរប្រពន្ធប្តី
គូដែលសប្បាយ គូលោកសេដ្ឋី
ឯគូភក្តី គឺចៅមាណព ។
ដោយសារតែស្រី
នាងគ្រប់លក្ខណ៍វៃ ឆ្លាតដឹងសព្វគ្រប់
ផ្តល់ជាយោបល់ មិនចេះឈរឈប់
ទើបចៅមាណព ស្គាល់អង្គក្សត្រា ។
មិនតែប៉ុណ្ណោះ
មង្គលរីកដុះ ពេញទាំងគ្រួសារ
កិត្តិយសរន្ទឺ សាយគ្រប់ទិសា
ឯនាយភេត្រា ធ្លាក់ខ្លួនសុំទាន ។

**ពូថៅយោងខុស**

លោកអ្នកចាំចុះ ជូនតាទូន្មាន
ឧសខ្លួតសាចត្រង់ ឧសថ្នាំងលឹបលៀន
សម្ងឹងឈរឈាន ចង់ពុះបំបែក ។
អោយប្រើពូថៅ
មានដង់ត្រឹមត្រូវ ចាត់ទុកជាឯក
ផ្ទៃស៊ីនឹងដង មិនបោរកោងកែក
ទុកដាក់តាមផ្នែក លំដាប់តូចធំ ។
ពេលយកទៅពុះ
មើលប្រភេទឧស ពុះឲ្យចំមុំ
បើឧសសាច់ត្រង់ ប្រើពូថៅធំ
មុខវាក្រពុំ ងាយបំបែកបាន ។
ឧសសាច់កណ្តាញ់
ប្រើអាល្មមវិញ ទើបវាចំណាន

មុខវាមុតល្អ កាប់ចាំងដេះបាន
ទោះថ្នាំងប៉ុន្មាន ពុះបានទាំងអស់ ។

**ច្រមុះយោងថ្លាល់**

អ្នកគិតឲ្យដល់ កុំធ្វើឡេះឡោះ
មិច្ឆាទិដ្ឋិ នាំឲ្យវង់គ្រោះ
ឃើញថ្លាល់គេស្រស់ ចង់ស្រោចស្រឹង្គារ ។

នទៀលផ្តេកផ្តិត
តាមវិស័យចិត្ត ស្រូបគន្ធមាលា
លើថ្លាល់ផ្ទូរផង់ នៃនាងពិម្ពា
ប្រតិព័ទ្ធវន្ទា នាំតែចំបែង ។

តាមពិតនាសា
យោងថ្លាល់អ្នកណា គឺយោងខ្លួនឯង
ថ្លាល់អន់តិចតួច ឲ្យតែវាខែង
ស្រួចស្រស់ចាំងចែង ដូចស្នែងកក្រ្គា ។

បើផែនថ្លាល់ក្ងោះ
មាននាសាខ្ពស់ ហើយទ្រង់វ៉ែនតា
នោះរឹតតែធ្វើ អោយវង់កក្រ្គា
លេចឡើងសង្ហា ដូចហង្សរបក្សី ។

តែផ្ទុយមកវិញ
ទោះថ្លាល់ប៉ោងពេញ រលោងម៉ដ្ឋខៃ
ចំណែកច្រមុះ ធំស្លៀតខើចខ្ចី
ក្រពិតអប្រិយ យោងថ្លាល់អីកើត ៕

ឆង ឈាង៍

*ដកស្រង់ចេញពី ទស្សនាវដ្តី កម្ពុជសុរិយា ខ្សែដដែល*